ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភារដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២១៨

ចុះថ្ងៃទី០៧ខែសីហាឆ្នាំ១៩៩៨

សាលដីកា

លេខ : ៧៧

ចុះថ្ងៃទី២២ខែមេសាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ប៉ែន ស៊ិន ជាចៅក្រម

៣- លោក ទៀវ ម៉ួន ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក ឈីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា ម៉េន សុខា

តំណាងអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ លើបណ្ដឹងសាទុក្ខពីសាលដីកាលេខ ១៨៦ ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦២៦ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្ដឹងសាទុក្ខឈ្មោះ សុខ សារុន ភេទស្រី អាយុ៥៧ឆ្នាំ ទីលំនៅផ្ទះលេខ ១២៨E ផ្លូវ ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

" លោក ជូ ចាន់ធារ៉ា ជាមេធាវី "

និងចុងចម្លើយបណ្ដឹងសាទុក្ខឈ្មោះ សុខ ភា ភេទស្រី អាយុ៧៥ឆ្នាំ ទីលំនៅផ្ទះលេខ ១២៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

កម្មវត្ថុបណ្ដឹង : ប្ដឹងទាមទារផ្ទះ

បានឃើញបណ្ដឹងសាទុក្ខលេខ១២១ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ១៩៩៨ របស់អ្នកស្រីសុខ សារុន ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៨៦ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២១៨ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ សុខ សារុន ចុះថ្ងៃទី២១ ខែ មិនា ឆ្នាំ១៩៩៦

ម្តងពីឈ្មោះ សុខ ភា ដែលបានរំលោភយកផ្ទះរបស់ខ្លួនលេខ ១២៨ [illegible] ផ្លូវ ១២២ ក្រុមទី ៥៦ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ដោយអាងហេតុថា កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៦ ខ្លួនបានផ្ញើផ្ទះទំនាស់ដែលមានអាសយដ្ឋានដូចខាងលើអោយក្មួយប្រុសរបស់ខ្លួនឈ្មោះ សុខ ផា មើលការខុសត្រូវ និង ថែរក្សាអោយដោយខ្លួនត្រូវព្យាបាលជំងឺនៅប្រទេស[illegible] ។ ក្នុងពេលកំពុងសំរាកព្យាបាលជំងឺបានរយះពេលប្រហែលមួយខែ ស្រាប់តែឈ្មោះ សុខ ភា បានកាត់សោរផ្ទះខ្លួនហើយចូលទៅនៅក្នុងផ្ទះនោះតែម្តងដោយដេញក្មួយរបស់ខ្លួនឈ្មោះ សុខ ផា អោយចេញពីផ្ទះនេះទៀតផង ។ ក្រោយពីខ្លួនត្រឡប់មកដល់ស្រុកខ្មែរវិញឈ្មោះ សុខ ភា ក៏បានដេញខ្លួនចេញព្រមទាំងប្រើពាក្យសំដីកំហែងទៀត ។

បានឃើញសាលក្រមលេខ ៣១ "ខ" ចុះថ្ងៃទី ១៥.០៥.៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ សុខ សារុន ចុះថ្ងៃទី ២១.០៣.៩៦ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលការផ្ទេរសិទ្ធិរបស់ឈ្មោះ សុខ សារុន ទៅអោយឈ្មោះ ទេស សារមឿន ចុះថ្ងៃទី ២៤.០៤.៩៧ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- ទទួលពាក្យបណ្តឹងសារត្រឡប់របស់ចុងចម្លើយចុះថ្ងៃទី ០៧.១០.៩៦ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្អែកពីគតិច្បាប់ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ីង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីការពីបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលចុងចម្លើយបានបង់រួចហើយ ។

៥- ផ្ទះលេខ ១២៨ [illegible] ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ត្រូវប្រគល់អោយឈ្មោះ សុខ សារុន ជាកម្មសិទ្ធិករចាប់ពីសាលក្រមចូលជាស្ថាពរ ។

៦- បង្គាប់អោយឈ្មោះ សុខ ភា និងគ្រួសារចុះចេញពីផ្ទះលេខ ១២៨ [illegible] ផ្លូវ ១២២ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ។ ចាប់ពីសាលក្រមមានប្រសិទ្ធិភាពអនុវត្ត ។

៧- បង្គាប់អោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ កាលបើហួសកំណត់ប្តឹងឧទ្ធរណ៍បង្គាប់អោយចុងចម្លើយសងប្រាក់ ៧.០០០៛ នេះទៅអោយដើមចោទវិញ និង បង្គាប់អោយឈ្មោះ សុខ ភា បង់ពន្ធសមាមាត្រចំនួន ១ភាគរយ លើតំលៃផ្ទះ ១១០តំលឹង មានតំលៃស្មើនឹង ១តំលឹង ១ជីមាសប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយ ។

៨- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវឧទ្ធរណ៍រយៈពេល ២ខែ ចាប់ពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៣ "ខ" ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ១៩៩៧ របស់ឈ្មោះ សុខ ភា ដែលប្តឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ ៣១ "ខ" ចុះថ្ងៃទី ១៥.០៥.៩៧ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការបៀបលេខ ១២ ចុះថ្ងៃទី ០៣.៣.៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- បង្គាប់អោយភាគីដើមចោទផ្តល់កិច្ចសន្យាលក់ ទិញផ្ទះ "ជាច្បាប់ដើម" ចុះថ្ងៃទី ០៦.៣.៩៣ មកតុលាការតាមសេចក្តីត្រូវការ ។

២- បង្គាប់អោយស្ថាប័នជំនាញធ្វើកោសល្យវិច័យនូវត្រាមេដៃរបស់អ្នកលក់ផ្ទះឈ្មោះ- ពេង ដុកគាវ និង នាង សុខ ភា ដែលមាននៅលើលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៥.៣.៩៣ អោយបានច្បាស់លាស់សិន មុននឹងសំរេចដល់អង្គសេចក្តី ។

៣- បង្គាប់អោយយកចម្លើយសាក្សីបន្ថែមទៀត កាលបើយល់ថាចាំបាច់ ។

៤- បង្គាប់អោយចុងចម្លើយចេញសាក្សីក្នុងការអង្កេតនេះ ។ សាលដីការបៀបនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

បានឃើញសាលដីកាលេខ១៨៦ ចុះថ្ងៃទី ០៤.៥.៩៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលបណ្តឹងឧទ្ធរណ៍របស់នាង សុខ ភា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមលេខ ៣១ "ខ" ចុះថ្ងៃទី ១៥.៥.៩៧ របស់តុលាការក្រុងភ្នំ-ពេញចោលជាអសារបង់ ។

ផ្ទះលេខ ១២៨ ខ ផ្លូវលេខ ១៦២ សង្កាត់ទឹកល្អក់ទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ មានវិញ្ញាបនបត្រសំគាល់អចលនវត្ថុលេខ ១៣១៦២ ចុះថ្ងៃទី ២១.១២.៩២ ត្រូវចែកតាមចំណែកដែលបានទិញចូលគ្នាគឺ ៖ នាង សុខ ភា ត្រូវបាន ៦៤,៧៩ ភាគរយ ។ នាង សុខ សារុន ត្រូវបាន ៣៥,២១ ភាគរយ ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ដែលនាង សុខ ភា បានបង់រួចហើយ គឺ ពន្ធហ៊ឹង និង ពន្ធចុះបញ្ជីក្តី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីការទទួលប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។ កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់អោយឈ្មោះ នាង សុខ សារុន សងប្រាក់ ១៣.០០០រៀល នេះ អោយទៅនាង សុខ ភា វិញ ។

បង្គាប់អោយ នាង សុខ សារុន បង់ពន្ធសមាមាត្រ ១ភាគរយ ទៅលើចំនួនប្រាក់ ៣៦,៧៥ តម្លឹងមាស ។

--៤---

បង្គាប់អោយនាង សុខ ភា បង់ពន្ធសមាមាត្រ ១ភាគរយ ទៅលើចំនួនប្រាក់ - ៣៧ ២៦ តម្លឹងមាស ។

ប្រាក់ពន្ធនេះ ៨០ភាគរយ ត្រូវបានជាប្រយោជន៍ថវិកាជាតិ និង ២ភាគរយត្រូវ បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៤- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខ នាង សុខ ភា កំបាំងមុខឈ្មោះ សុខ សារុន បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១២១ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ១៩៩៨ របស់អ្នកស្រី សុខ សារុន ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី២៥.៨.៩៨ របស់ឈ្មោះ ហុង ឫទ្ធិហុន

បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី ០៤.៩.៩៨ របស់ឈ្មោះ ប៊ុល ផារី ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា:-

សាលដីការដ្ឋប្បវេណីលេខ ១៨២ ចុះថ្ងៃទី ០៤.០៥.៩៨ របស់សាលាឧទ្ធរណ៍ ដែល បានសំរេចសេចក្តីមកនេះមានលក្ខណៈផ្ទុយនឹងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ សុខ សារុន ជាដើមចោទ និង ជាដើម បណ្តឹងសាទុក្ខ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ ភា ជាចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខ នៅ ពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា: ខ្លួនសូមឆ្លើយបដិសេធនូវសារណារបស់គាត់ ខ្លួនបានទិញផ្ទះនេះ ចូលគាត់ ដើម្បីអោយគាត់បានមកស្នាក់នៅមួយខ្ញាលនៅពេលមកពីស្រុកបារាំង ហើយខ្លួនសុំតម្កល់ សាលដីការបស់សាលាឧទ្ធរណ៍នៅដដែល ។

លោក ជូ ចាន់ធីរ៉ា ជាមេធាវីរបស់អ្នកស្រី សុខ សារុន បានថ្លឹងសន្និដ្ឋានថា: ផ្ទះទំនាស់លេខ ១២៨ សេរីសូទ្យុតិ១ អ្នកស្រី សុខ សារុន បានទិញពីឈ្មោះ ទេង ផុកគាវ និង ប្រពន្ធឈ្មោះ កាត់ វណ្ណី ក្នុងតម្លៃ ១១០តម្លឹងមាស ។ ក្នុងការទិញនេះ គឺប្រគល់លុយអោយជា ពីរដំណាក់កាល គឺលើកទី ១ នៅថ្ងៃទី ៦.៣.៩៣ ចំនួន ២៨.០០០ដុល្លា គិតជាមាសចំនួន ៧១តម្លឹង ២ជី ៦ហុន និង លើកទី ២ នៅថ្ងៃទី ២២.៦.៩៣ ចំនួន ១៧.០០០ដុល្លា ស្មើនឹងមាស ៣៨តម្លឹង ៧ជី ៤ហុន ដោយមានធ្វើកិច្ចសន្យាទិញលក់ នៅចំពោះមុខសាក្សីឈ្មោះ គង់ ចេក ។

សំណូមពរ : សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍

សុំអោយតុលាការទទួលស្គាល់អ្នកស្រី សុខ សារុន ជាម្ចាស់កម្មសិទ្ធិតាម ច្បាប់ ។

សុំអោយអ្នកស្រី សុខ ភា ចុះចេញពីផ្ទះនេះ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់អ្នកស្រី សុខ សារុន ចម្លើយរបស់អ្នកស្រី សុខ ភា និង សេចក្តីសន្និដ្ឋាន របស់មេធាវីដើមចោទ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១២១ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់អ្នកស្រី សុខ សារុន ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចបែងចែកផ្ទះទំនាស់លេខ១២៨សេរីសូភ័ន្ត អឺ១ សង្កាត់ ទឹកល្អក់ទី ១ ខណ្ឌ ទួលគោក តាមចំណែកដែលបានទិញចូលគ្នាគឺនាង សុខ ភា ត្រូវបាន ៦៤,៧៩ ភាគរយ និង នាង សុខ សារុន ត្រូវបាន ៣៥,២១ភាគរយ ដោយសំអាងទៅលើការអះអាងរបស់នាង សុខ ភា និង កិច្ចសន្យាផ្ទេរសិទ្ធិគ្រប់គ្រងផ្ទះទំនាស់ ចុះថ្ងៃទី ១៥.៣.៨៣ នោះគឺជាការភន្តច្រឡំពីព្រោះថា:-

- ការអះអាងរបស់អ្នកស្រី សុខ ភា ដែលថា ក្នុងការទិញផ្ទះទំនាស់នេះឪពុករបស់អ្នកស្រីឈ្មោះ សុខ គឹមហាក់ បានចេញប្រាក់ ចំនួន ៧១តម្លឹង ២៦ហ៊ុន ហើយអ្នកស្រី សុខ សារុន បានចេញប្រាក់ ចំនួន ៣៨តម្លឹង ៧៤ហ៊ុនមាសនោះពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជាការពិតបានឡើយ ។

- កិច្ចសន្យាផ្ទេរសិទ្ធិគ្រប់គ្រងផ្ទះទំនាស់ ចុះថ្ងៃទី ១៥.៣.៨៣ ដែលសាលាឧទ្ធរណ៍ពិចារណាថា ជាច្បាប់ដើមធ្វើនៅចំពោះមុខគណៈកម្មាធិការប្រជាជនសង្កាត់ តាមពិតវាជាលិខិតថតចម្លងមានតែកាលបរិច្ឆេទ ថ្ងៃ និង ខែ ពុំមានកាលបរិច្ឆេទឆ្នាំទេ ។ ម្យ៉ាងទៀតនៅលើកិច្ចសន្យានេះមានតែស្នាមមេដៃអ្នកប្រគល់ ដែលពុំមានឈ្មោះ និង ស្នាមមេដៃអ្នកទទួលគឺនាង សុខ ភា ពុំមានសេចក្តីបញ្ជាក់របស់រដ្ឋអំណាចសង្កាត់ថា ជាស្នាមមេដៃរបស់អ្នកណា ហើយក៏ពុំមានបញ្ជាក់ពីចំនួនទឹកប្រាក់ដែលភាគីនិមួយៗ ត្រូវចេញនោះឡើយ ។

- យល់ឃើញថា នៅចំពោះមុខតុលាការថ្នាក់ក្រោមម្ចាស់ផ្ទះដើមលោកហេង ផុកតាវ និង អ្នកស្រី កាក់ វ៉ាន់ឌី បានអះអាងថា ខ្លួនពិតជាបានលក់ផ្ទះទំនាស់អោយអ្នកស្រីសុខសារុន ហើយបានទទួលលុយគ្រប់ចំនួនពីអ្នកស្រី សុខ សារុន ព្រមទាំងបានបំពេញសំណុំបែបបទផ្ទេរសិទ្ធិអោយអ្នកស្រី សុខ សារុន គ្រប់សព្វអស់ហើយៗ អ្នកស្រីសុខ សារុន ក៏បានចូលស្នាក់នៅផ្ទះទំនាស់នេះដែរ ដែលកំណត់ថា អ្នកស្រី សុខ សារុន បានទិញផ្ទះទំនាស់ដាច់តែឯងពីអ្នកស្រី ពុំមានភស្តុតាងណាបញ្ជាក់ថា មានការចូលរួមពីអ្នកស្រី សុខ ភា ទេ ។

--- ៦ --

- យល់ឃើញថា ខ្លឹមសារនៃកិច្ចសន្យាទិញលក់ផ្ទះចំនាស់ ចុះថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ១៩៩៣ បានបញ្ជាក់ថា អ្នកស្រី សុខ សារុន បានប្រគល់មាសមុន ចំនួន ៧១ តម្លឹង ២៦ហ៊ុន និង ចំនួន ៣៨តម្លឹង ៧៤ហ៊ុន នៅថ្ងៃទី ២២.៦.៩៣ សរុប ១១០តម្លឹងមាស អោយទៅលោក ទេង ផុកគាវ និង អ្នកស្រី កាក់ វណ្ណឌី ជាប្រពន្ធហើយពុំមាននិទ្ទេសថា មានការទទួលមាសពីលោក សុខ គឹមហាក់ ឬ ពី អ្នកស្រី សុខ ភា ទេឡើយ ។

- យល់ឃើញថា អ្នកស្រី សុខ សារុន បានធ្វើសារណាការពាររឿងក្តីរបស់អ្នកស្រី ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះកំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៨៦ ចុះថ្ងៃទី ០៥.៥.១៩៩៨ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកស្រី សុខ ភា កំបាំងមុខអ្នកស្រី សុខ សារុន ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

១- ទទួលបណ្តឹងសាទុក្ខលេខ ១២១ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់ អ្នកស្រី សុខ សារុន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១៨៦ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២១៨ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០រៀល ដែលអ្នកស្រី សុខ ភា បានបង់ ជូនគឺ :-

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីការទិញប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៩ ។